Disability Rights California

*ប្រព័ន្ធការពារ និងការតស៊ូមតិរបស់រដ្ឋកាលីហ្វ័រនីញ៉ា*

# ការយល់ដឹងអំពីច្បាប់លែនធឺមែន-ផឺទ្រិស-ហ្ស៊ត (LPS, Lanterman-Petris-Short)

*ឯកសារបោះពុម្ពផ្សាយលេខ* **#5608.06-Cambodian**

## ជំពូកទី 1 ៖ ការឃុំខ្លួនអ្នកជម្ងឺដើម្បីផ្តល់ការព្យាបាលដោយមិនស្ម័គ្រចិត្តពីអ្នកជម្ងឺ

ច្បាប់រដ្ឋកាលីហ្វ័រនីញ៉ា អនុញ្ញាតឲ្យមន្ត្រីនគរបាល និងអ្នកមានវិជ្ជាជីវៈផ្នែកសុខភាពផ្លូវចិត្តមួយចំនួន អាចឃុំឃាំងអ្នកបាន បើពួកគេជឿថា ដោយសារតែស្ថានភាពជម្ងឺផ្លូវចិត្តរបស់អ្នក វាអាចនាំឲ្យអ្នកបង្ក ឬធ្វើឲ្យមានគ្រោះថ្នាក់អ្វីមួយកើតឡើង ។ សកម្មភាពឃុំឃាំងនេះ ជាធម្មតាគេហៅថា “ការឃុំឃាំង5150 (5150 hold)” ដែលគេហៅតាមឈ្មោះច្បាប់ដែលបានអនុញ្ញាតឲ្យធ្វើដូច្នេះ ។ ក្រមសុខុមាលភាព និងវិទ្យាស្ថាន (WIC, Welf. & Inst. Code) § 5150 ។

ស្ថិតក្រោមច្បាប់នេះ បើអ្នកស្ថិតក្នុងលក្ខណៈវិនិច្ឆ័យជាក់លាក់ណាមួយ គឺមានន័យថា គេអាចឃុំឃាំងអ្នករហូតដល់ទៅ 72 ម៉ោង ។ ការចាប់ឃុំនេះ គេមិនហៅថាជាការចាប់ដោយសារមូលហេតុអំពើឧក្រិដ្ឋកម្មឡើយ ។ នៅក្នុងអំឡុងពេលដែលគេឃុំខ្លួនអ្នក អ្នកឯកទេសជម្ងឺផ្លូវចិត្ត នឹងពិនិត្យស្ថានភាពជម្ងឺរបស់អ្នក ដើម្បីសម្រេចថា តើគេអាចដោះលែងអ្នកឲ្យនៅក្រៅឃុំបានដែរឬទេ ពិនិត្យមើលថាតើ អ្នកអាចព្រមទទួលសេវាកម្មដោយស្ម័គ្រចិត្ត ឬថាតើអ្នកត្រូវការការព្យាបាលបន្ថែមទៀតដែរឬទេ ។ ក្រមសុខុមាលភាព និងវិទ្យាស្ថាន §§ 5151, 5152 ។ បើអ្នកឯកទេស សម្រេចថា អ្នកត្រូវការការព្យាបាលបន្ថែម ហើយបើពួកគេមានជំនឿផងដែរថា អ្នកមិនមានបំណង ឬមិនអាចទទួលការព្យាបាលដោយស្ម័គ្រចិត្តបានទេនោះ ពួកគេអាចសម្រេចឃុំខ្លួនអ្នកបន្ថែមចំនួន 14 ថ្ងៃជាបន្តទៀត ។ ក្រមសុខុមាលភាព និងវិទ្យាស្ថាន § 5250 ។

### លក្ខណៈវិនិច្ឆ័យចំពោះការឃុំខ្លួនអ្នកជម្ងឺ

មន្ត្រីនគរបាល ឬអ្នកឯកទេសជម្ងឺផ្លូវចិត្ត មិនអាចឃុំខ្លួនអ្នក ដោយសារតែអ្នកមានជម្ងឺផ្លូវចិត្តឡើយ ។ គេអាចឃុំខ្លួនអ្នកបាន ក្នុងករណីដែលពួកគេមានជំនឿថា ជម្ងឺផ្លូវចិត្តរបស់អ្នក អាចធ្វើឲ្យអ្នកបង្កគ្រោះថ្នាក់អ្វីមួយបាន ។ ក្រមសុខុមាលភាព និងវិទ្យាស្ថាន § 5150.05 ។ មន្ត្រីនគរបាល ឬអ្នកព្យាបាលរូបអ្នក អាចពិនិត្យមើលប្រវត្តិជម្ងឺផ្លូវចិត្តរបស់អ្នក តែគេមិនអាចឃុំខ្លួនអ្នកដោយសារតែប្រវត្តិជម្ងឺរបស់អ្នកតែមួយមុខបានឡើយ ។ ដើម្បីឃុំខ្លួនអ្នកជម្ងឺបាន យ៉ាងហោចណាស់ អ្នកត្រូវស្ថិតក្នុងចំណុចនៃលក្ខណៈវិនិច្ឆ័យដូចខាងក្រោម ដែលបណ្តាលមកពីស្ថានភាពជម្ងឺផ្លូវចិត្ត ៖

### បង្កគ្រោះថ្នាក់ចំពោះខ្លួនឯង

ភាគច្រើន អ្នកជម្ងឺដែលគេគិតថាជាអ្នកបង្កគ្រោះថ្នាក់ចំពោះខ្លួនឯង តែងគម្រាម ឬប៉ុនប៉ងបង្ករបួសស្នាមដល់ខ្លួនឯង ឬសម្លាប់ខ្លួន ។

### បង្កគ្រោះថ្នាក់ចំពោះអ្នកដទៃ

ការគម្រាមកំហែង ឬការប៉ុនប៉ងជាក់ស្តែងក្នុងការធ្វើឲ្យអ្នកដទៃមានរបួសស្នាម គឺជាវិធីសាមញ្ញបំផុត ដែលស្ថិតក្នុងលក្ខណៈវិនិច្ឆ័យនេះ ។

### ពិការភាពធ្ងន់ធ្ងរ

អ្នកដែលមាន "ពិការភាពធ្ងន់ធ្ងរ" មានន័យថា អ្នកនោះលែងអាចទទួលទានអាហារ ស្លៀកពាក់ ឬរស់នៅដោយខ្លួនឯងបាន ដោយសារតែបញ្ហាជម្ងឺផ្លូវចិត្ត ។ ក្រមសុខុមាលភាព និងវិទ្យាស្ថាន § 5008(h) ។ ឧទាហរណ៍ មនុស្សម្នាក់ត្រូវគេគិតថាជាមនុស្សមានពិការភាពធ្ងន់ធ្ងរ បើអ្នកនោះមិនព្រមទទួលទានអាហារឲ្យបានគ្រប់គ្រាន់ដើម្បីរស់ ឬលែងមានសមត្ថភាពអាចថែទាំផ្ទះរបស់ខ្លួនបាន ។

### ព័ត៌មានបន្ថែមចំពោះពិការភាពធ្ងន់ធ្ងរ

បុគ្គលដែលលែងមានសមត្ថភាពអាចថែទាំខ្លួនឯងបាន តែអាចរស់នៅដោយមានសុវត្ថិភាពបានបើមានបុគ្គលទីបីជាអ្នកជួយ អាចមិនមែនជាមនុស្សដែលមាន "ពិការភាពធ្ងន់ធ្ងរ" ឡើយ ។ § 5350(3) ។ *សូមអានផងដែរឯកសារស្តីការមើលថែទាំអ្នកជម្ងឺ ដោយការចាត់តាំងរបស់តុលាការ* 35 Cal ។ 3d 244, 253, 673 P.2d 209 (1983) (សម្រង់ប្រភពព័ត៌មានយោងត្រូវបានដកចេញ) "...ការបង្ខំឲ្យគេធ្វើជាអ្នកមើលថែទាំអ្នកជម្ងឺ ត្រូវធ្វើឡើងតែក្នុងករណីដែលជាការចាំបាច់យ៉ាងពិតប្រាកដ ។ ដើម្បីអាចសម្រេចគោលបំណងនេះបាន ភស្តុតាងដែលបញ្ជាក់ថាមានជំនួយពីភាគីទីបី ត្រូវយកមកពិចារណា" *និង O'Connor v. Donaldson*, 422 U.S. 563, 575, 95 S. Ct. 2486, 2493–94, 45 L. Ed. 2d 396 (1975) "...ខណៈពេលដែលរដ្ឋអាចយកជាហេតុផលសម្រាប់អះអាងថា យើងឃុំខ្លួនអ្នកជម្ងឺ ដើម្បីបង្ការកុំឲ្យគេមានគ្រោះថ្នាក់ ចំពោះការដាក់ពន្ធនាគារវិញ គឺកម្រកើតមានណាស់ ប្រសិនបើមិនមានស្ថានភាពចាំបាច់សម្រាប់ពង្រឹងបទដ្ឋានរស់នៅរបស់អ្នកជម្ងឺដែលអាចរស់នៅបានដោយសុវត្ថភាពក្នុងស្ថានភាពមានសេរីភាព គឺអាចរស់នៅបានដោយខ្លួនឯង ឬអាចរស់នៅបានដោយមានជំនួយពីគ្រួសារ ឬពីមិត្តភ័ក្តិ" ។

ភាពជាជនអនាថាតែមួយមុខ គឺហាក់ដូចជាមិនស្ថិតក្នុងលក្ខណៈវិនិច្ឆ័យជាមនុស្សមាន "ពិការភាពធ្ងន់ធ្ងរ" ឡើយ ។ ទោះជាយ៉ាងណាក៏ដោយ ចំពោះអ្នកដែលមិនអាច ឬដែលមិនព្យាយាមរកអាហារ ឬទីជម្រកដោយខ្លួនឯងបាន ដែលបណ្តាលដោយផ្ទាល់មកពីស្ថានភាពជម្ងឺផ្លូវចិត្ត អាចត្រូវពិចារណាថាជាមនុស្សដែលមានពិការភាពធ្ងន់ធ្ងរ ។ សូ*មអាន ក្រុមមើលខុសត្រូវអ្នកជម្ងឺដោយការតែងតាំងរបស់តុលាការ*, 71 Cal. App. 3d 277, 284, 139 Cal. Rptr. 357 (Ct. App. 1977) ("...ពាក្យថា [ពិការភាពធ្ងន់ធ្ងរ) គឺមានន័យច្បាស់លាស់គ្រប់គ្រាន់ ក្នុងការមិនរាប់បញ្ចូលចំពោះការរស់នៅខុសពីធម្មតា ឬការរស់នៅខុសគេ ។ វាជាពាក្យមួយដែលសំដៅលើការអសមត្ថភាព ឬការបដិសេធពីសំណាកអ្នកដែលត្រូវការគេជួយមើលថែ ក្នុងការមើលថែទាំសេចក្តីត្រូវការជាមូលដ្ឋានរបស់ខ្លួនផ្នែកចំណីអាហារ សម្លៀកបំពាក់ និងទីជម្រក") ។

បើទោះបីជា សកម្មភាពកន្លងមក របស់អ្នកជម្ងឺ អាចត្រូវបានគេយកមកពិចារណាក៏ដោយ ក៏អ្នកនោះមិនត្រូវបានគេគិតថាជាមនុស្សមានពិការភាពធ្ងន់ធ្ងរឡើយ ប្រសិនបើក្នុងពេលចំពោះមុខ បុគ្គលនោះមិនបានបង្ហាញឲ្យឃើញនូវស្ថានភាពបង្កគ្រោះថ្នាក់ចំពោះខ្លួនឯង ដោយសារតែភាពអសមត្ថភាពក្នុងការ

ថែទាំខ្លួនឯង ។ *សូមអានការតែងតាំងអ្នកមើលថែទាំរបស់លោក Benevuto* 180 Cal.App.3d 1030 (1986) ។ ស្ថានភាពក្នុងការបង្កគ្រោះថ្នាក់នាពេលអនាគត ក៏មិនអាចមានភាពគ្រប់គ្រាន់ ក្នុងការចាត់ចូលថាត្រូវតាមលក្ខណៈវិនិច្ឆ័យឡើយ ។ *Id* at 1034 n.2. ("បើការតែងតាំងអ្នកមើលខុសត្រូវក្រោមច្បាប់ LPS អាចយកមកអនុវត្តឡើងវិញ ដោយសារតែការគិតថាថ្ងៃមុខស្ថានភាពគ្រោះថ្នាក់អាចកើតឡើងវិញបាន នោះមនុស្សមួយចំនួនដែលទទួលបានអ្នកមើលថែទាំដែលមិនបង្កស្ថានភាពគ្រោះថ្នាក់ឡើងវិញ នឹងត្រូវបានគេដកហូតសេរីភាពដោយសំអាងលើគំនិតគិតស្មានបែបទុទិដ្ឋិនិយម ។ តម្លៃនេះ មិនបានទទួលការធានាឡើយ ដោយគិតអំពីនីតិវិធីនៃលក្ខន្តិកៈ ដែលអាចយកមកប្រើបានភ្លាមៗ ដើម្បីអនុវត្តឡើងវិញនូវច្បាប់ LPS ចំពោះការផ្តល់អ្នកមើលថែទាំតាមការចាត់តាំងរបស់តុលាការ បើជាការចាំបាច់") ។

*ចំណាំ* ៖ ច្បាប់ស្រដៀងគ្នានេះ អនុញ្ញាតឲ្យនគរបាល (ឬអ្នកដែលបានទទួលការតែងតាំង) អាចឃុំខ្លួនអ្នកបាន បើពួកគេគិតថា អ្នកស្ថិតក្នុងលក្ខណៈវិនិច្ឆ័យខាងលើ ដោយសារតែភាពញៀនសុរ៉ាវ៉ារ៉ៃ ។ ក្រមសុខុមាលភាព និងវិទ្យាស្ថាន § 5170 ។

## ការឃុំខ្លួន "5150" ចំនួន 72 ម៉ោង

នៅក្នុងពេលចាប់ផ្តើមនៃការឃុំខ្លួន គេត្រូវយកអ្នកទៅកាន់មន្ទីរពេទ្យឆ្កួត ឬមន្ទីរមើលថែទាំអ្នកជម្ងឺផ្លូវចិត្ត ដើម្បីឲ្យអ្នកឯកទេសវាយតម្លៃស្ថានភាពជម្ងឺ របស់អ្នក ។ ក្នុងពេលដែលអ្នកស្ថិតនៅក្នុងមន្ទីរពេទ្យ បុគ្គលិកពេទ្យនឹងកំណត់មើលថាតើគេត្រូវស្នើសុំឲ្យឃុំខ្លួនអ្នកក្នុងរយៈពេលវែងដើម្បីព្យាបាល ឬក៏សម្រេចថាតើគេអាចដោះលែងអ្នកបានដែរឬទេ ។

ខាងមន្ទីរពេទ្យមិនចាំបាច់ឃុំខ្លួនអ្នករហូតដល់ 72 ម៉ោងពេញឡើយ ។ ក្រមសុខុមាលភាព និងវិទ្យាស្ថាន § 5152 ។ មន្ទីរពេទ្យអាចដោះលែងអ្នកក្រោយពីឃុំខ្លួនក្នុងរយៈពេលខ្លី បើពួកគេជឿថា គេលែងត្រូវការវាយតម្លៃ ឬព្យាបាលអ្នកតទៅទៀតហើយ ។

នៅចុងបញ្ចប់នៃការឃុំខ្លួនចំនួន 72ម៉ោង នឹងមានអ្វីមួយកើតឡើង ក្នុងចំណោមចំណុចមួយចំនួនខាងក្រោម ៖

- អ្នកនឹងត្រូវទទួលការដោះលែង ឬ
- អ្នកត្រូវបន្តស្ថិតនៅទីនោះ ក្នុងនាមជាអ្នកជម្ងឺស្ម័គ្រចិត្តចូលទទួលការព្យាបាល ឬ
- អ្នកត្រូវគេឃុំខ្លួនដោយមិនស្ម័គ្រចិត្តចំនួន 14 ថ្ងៃ (ដែលគេហៅថា "ការបញ្ជាក់សម្រាប់ទទួលការព្យាបាលជម្ងឺក្នុងលក្ខណៈល្អិតល្អន់ (Certification for Intensive Treatment) ឬ
- គេនឹងបញ្ជូនអ្នកឲ្យស្ថិតក្រោមការមើលថែពីមនុស្សដែលចាត់តាំងដោយតុលាការ ។ *សូមអាន* "ជំពូកទី2 ៖ ការមើលថែពីមនុស្សដែលចាត់តាំងដោយតុលាការ ក្រោមច្បាប់ LPS ។

### សិទ្ធិរបស់អ្នកក្នុងពេលស្ថិតក្រោមការឃុំខ្លួនចំនួន 72 ម៉ោង

ការឃុំខ្លួនដោយមិនស្ម័គ្រចិត្ត គឺមិនមែនជាការចាប់ខ្លួនដោយសារអំពើឧក្រិដ្ឋកម្មឡើយ ។ ក្នុងពេលជាប់ឃុំ អ្នកនៅរក្សាបានសិទ្ធិមួយចំនួន ។

- **ទ្រព្យសម្បត្តិ** ៖ បុគ្គលដែលចាប់រូបអ្នកដាក់ចូលមន្ទីរឃុំឃាំង ត្រូវទទួលខុសត្រូវ ដោយហ្មត់ចត់ក្នុងការយាមកាមទ្រព្យសម្បត្តិរបស់អ្នកឲ្យនៅគង់វង្ស ។ គេត្រូវអនុញ្ញាតឲ្យអ្នកយកទ្រព្យសម្បត្តិផ្ទាល់ខ្លួនមួយចំនួនដាក់ជាប់ខ្លួន ។ ក្រមសុខុមាលភាព និងវិទ្យាស្ថាន § 5210 ។

- **ការហៅទូរស័ព្ទ ៖** បុគ្គលដែលចាប់រូបអ្នកដាក់ក្នុងឃុំ ត្រូវប្រាប់អ្នកឲ្យបានដឹងថា អ្នកអាច ហៅទូរស័ព្ទដើម្បីប្រាប់ឲ្យនរណាម្នាក់ដឹងថា តើគេយករូបអ្នកទៅទីណា ។ ក្រមសុខុមាលភាព និងវិទ្យាស្ថាន § 5150(g)(1) ។

- **សេចក្តីជូនដំណឹង និងការវាយតម្លៃ ៖** អ្នកត្រូវទទួលបានសំណៅជាលាយល័ក្ខណ៍អក្សរចំពោះញត្តិ ដែលពន្យល់អំពីមូលហេតុដែលគេឃុំខ្លួនអ្នក ដើម្បីធ្វើការវាយតម្លៃ ។ ក្រមសុខុមាលភាព និងវិទ្យាស្ថាន § 5208 ។ នៅក្នុងញត្តិនេះ ត្រូវមានសរសេរឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ញត្តិ ឈ្មោះ និងព័ត៍មាន អត្តសញ្ញាណកម្មផ្សេងទៀតរបស់អ្នក ដូចជា អាសយដ្ឋាន ភេទ និងមុខរបរ ព័ត៍មានបញ្ជាក់ការពិតដែលយកមកប្រើ ជាមូលដ្ឋានសម្រាប់សរសេរញត្តិ ឈ្មោះរបស់អ្នកដែលគេជឿថាជាអ្នកទទួលខុសត្រូវក្នុងការមើលថែទាំរូបអ្នក និងព័ត៍មានផ្សេងទៀត ដែលតុលាការអាចសួររក ។ ក្រមសុខុមាលភាព និងវិទ្យាស្ថាន § 5204 ។ ក្នុងពេលដែលគេឃុំខ្លួនអ្នក មន្ទីរពេទ្យត្រូវតែវាយតម្លៃអំពីស្ថានភាពជម្ងឺរបស់អ្នក ។ អ្នកធ្វើការវាយតម្លៃស្ថានភាពជម្ងឺរបស់អ្នក ត្រូវពិចារណាតាំងពីស្ថានភាពវេជ្ជសាស្ត្រ ចិត្តសាស្ត្រ ការអប់រំ សង្គម ហិរញ្ញវត្ថុ និងស្ថានភាព ផ្លូវច្បាប់របស់អ្នក ។ ក្រមសុខុមាលភាព និងវិទ្យាស្ថាន § 5008 ។

- **ការប្រើថ្នាំព្យាបាលរោគចិត្ត ៖** អ្នកមានសិទ្ធិទទួល ឬបដិសេធការប្រើថ្នាំព្យាបាលរោគចិត្ត ។ គេអាច ឲ្យអ្នកប្រើថ្នាំប្រភេទនេះបាន ក្រោយពេលគ្រូពេទ្យផ្តល់ឲ្យអ្នកនូវព័ត៍ជាលាយល័ក្ខណ៍អក្សរ និងព័ត៍មាន ផ្ទាល់មាត់អំពីប្រសិទ្ធិភាព និងផលប៉ះពាល់របស់ថ្នាំដែលអ្នកត្រូវប្រើ ហើយអ្នកក៏បានផ្តល់ការ យល់ព្រមជាលាយល័ក្ខណ៍អក្សរក្នុងការប្រើថ្នាំប្រភេទនេះ ។ តែទោះជាយ៉ាងណាក៏ដោយ ចំពោះស្ថានភាពគ្រាអាសន្នមួយចំនួន គេត្រូវបង្ខំឲ្យអ្នកប្រើថ្នាំដើម្បីព្យាបាលរោគចិត្ត ។ គេក៏អាចបង្ខំ ឲ្យអ្នកប្រើថ្នាំព្យាបាលរោគចិត្តដែរ ប្រសិនបើក្រោយពេលសវនាការ ចៅក្រមសម្រេចថា អ្នកខ្វះសមត្ថភាពក្នុងការសម្រេចចិត្តលើការព្រម ឬមិនព្រមប្រើប្រាស់ថ្នាំដើម្បីព្យាបាលរោគចិត្ត ។ ក្រមសុខុមាលភាព និងវិទ្យាស្ថាន § 5332 ។

## សវនាការដើម្បីពិនិត្យសេចក្តីបញ្ជាក់ឡើងវិញ និងការឃុំខ្លួន “5250” ចំនួន 14 ថ្ងៃ

ប្រសិនបើមន្ទីរព្យាបាល ត្រូវការឃុំខ្លួនអ្នកយូរជាង 72 ម៉ោង អ្នកមានសិទ្ធិទទួលបាន ការធ្វើសវនាការដើម្បីពិនិត្យសេចក្តីបញ្ជាក់ឡើងវិញ (Certification Review Hearing) ។ នៅក្នុងពេលនេះ អ្នកមានសិទ្ធិទទួលបានការជូនដំណឹងជាលាយល័ក្ខណ៍អក្សរ អំពីការឃុំខ្លួនរបស់អ្នក ។ សេចក្តីជូនដំណឹងនេះ ត្រូវ រួមបញ្ចូលនូវមូលហេតុជាក់លាក់ ក្នុងការឃុំខ្លួនអ្នក ។ ក្រមសុខុមាលភាព និងវិទ្យាស្ថាន § 5251 ។ អ្នកក៏មានសិទ្ធិទទួលបានជំនួយពីក្រុមតស៊ូមតិដើម្បីសិទ្ធិអ្នកជម្ងឺ ផងដែរ ។ ក្រុមតស៊ូមតិដើម្បីសិទ្ធិអ្នកជម្ងឺ គឺជាក្រុមមនុស្សសម្រាប់ជួយអ្នកជម្ងឺឲ្យបានយល់អំពីសិទ្ធិរបស់ខ្លួន និងធ្វើការតស៊ូមតិដើម្បីប្រយោជន៍របស់អ្នក ជម្ងឺ ។ ក្រមសុខុមាលភាព និងវិទ្យាស្ថាន § 5325(h) ។ សវនាការនេះ ត្រូវតែរៀបចំដំណើរការឲ្យបានក្នុងរវាងបួនថ្ងៃ

គិតចាប់ពីថ្ងៃដែលអ្នកបានទទួលការបញ្ជាក់ថាត្រូវស្ថិតក្នុងការឃុំខ្លួនចំនួន 14 ថ្ងៃ ប្រសិនបើអ្នក ឬមេធាវីរបស់អ្នក មិនបានស្នើសុំការពន្យារពេលទេនោះ ។ ក្រមសុខុមាលភាព និងវិទ្យាស្ថាន §§ 5250, 5254 ។ អ្នកមិនចាំបាច់ ស្នើសុំឲ្យមានសវនាការនេះឡើយ ដោយសារថា គេនឹងរៀបចំឲ្យអ្នកដោយស្វ័យប្រវត្តិ ។

នៅក្នុងសវនាការ ភាគីអព្យាក្រិតមួយនឹងធ្វើការពិនិត្យឡើងវិញពីសំណុំរឿងរបស់អ្នក ដើម្បីរកមើលថាតើមានភស្តុតាងគ្រប់គ្រាន់ (ដែលគេហៅថា "បុព្វហេតុដែលអាចមាន" (Probable Cause) ដើម្បីបន្តឃុំខ្លួនអ្នកដោយបង្ខំដែរឬទេ ។ សវនាការនេះ ត្រូវបានរៀបចំឡើងដើម្បីអត្ថប្រយោជន៍របស់អ្នក ហើយមន្ទីរពេទ្យត្រូវទទួលបន្ទុកបញ្ជាក់អំណះអំណាងក្នុងការបន្តការឃុំខ្លួនអ្នក ។ អ្នកមិនចាំបាច់រកភស្តុតាងមកបញ្ជាក់ថាហេតុអ្វីក៏មន្ទីរពេទ្យមិនត្រូវឃុំខ្លួនអ្នកឡើយ តែអ្នកមានសិទ្ធិបង្ហាញភស្តុតាងថាហេតុអ្វីក៏មន្ទីរពេទ្យមិនត្រូវបន្តឃុំខ្លួនអ្នកទៀត ។ បើភាគីជាអ្នកធ្វើសវនាការ កំណត់ឃើញថា មិនមានភស្តុតាងគ្រប់គ្រាន់ដែលត្រូវឃុំខ្លួនអ្នក មន្ទីរពេទ្យត្រូវតែដោះលែងរូបអ្នកចេញពីការឃុំឃាំង ។ ក្រមសុខុមាលភាព និងវិទ្យាស្ថាន § 5256 ។

សិទ្ធិរបស់អ្នកក្នុងអំឡុងពេលធ្វើសវនាការពិនិត្យការបញ្ជាក់ឡើងវិញ

អ្នកត្រូវទទួលបានសិទ្ធិជាក់លាក់ និងការ
ការពារមួយចំនួននៅក្នុងអំឡុងពេលធ្វើសវនាការពនិត្យការបញ្ជាក់ឡើងវិញ (Certification Review Hearing)[1] ។ សិទ្ធិទាំងអស់នេះ គឺរួមបញ្ចូលនូវ ៖

- សិទ្ធិទទួលបានជំនួយពីមេធាវី ឬស្មាក្តីផ្សេងទៀត

- សិទ្ធិបង្ហាញភស្តុតាង សម្រាប់ខ្លួនឯង

- សិទ្ធិចំពោះការសួរនាំបុគ្គលដែលយកភស្តុតាងមកបង្ហាញ ដើម្បីគាំទ្រសេចក្តីបញ្ជាក់ឲ្យឃុំខ្លួនអ្នក

- សិទ្ធិស្នើសុំសមហេតុផល ឲ្យមនុស្សនៅក្នុងមន្ទីរព្យាបាល ចូលរួមសវនាការ

- បើគេឲ្យថ្នាំអ្នកលេបក្នុងរវាង 24ម៉ោង មុនការបើកសវនាការរបស់អ្នក គេត្រូវប្រាប់ដំណឹងនេះឲ្យអ្នកធ្វើសវនាការបានដឹងថាអ្នកបានលេបថ្នាំ ព្រមទាំងប្រាប់ពីផលប៉ះពាល់ដែលថ្នាំនេះមានចំពោះរូបអ្នក ។

សវនាការរបស់អ្នក អាចមានភាពផ្លូវការតិចជាងសវនាការមួយចំនួនធំដែលរៀបចំឡើងដោយតុលាការ ។ ការធ្វើដូច្នេះ គឺជាការជម្រុញឲ្យអ្នកចូលរួមអាចបញ្ចេញយោបល់ដោយបើកចំហអំពីការបញ្ជាក់ឲ្យឃុំខ្លួនអ្នក ។ បុគ្គលិករបស់មន្ទីរព្យាបាល ត្រូវផ្តល់ដំណឹងដល់សមាជិកគ្រួយសារ

[1] បើអ្នកចង់មើលលក្ខន្តិកៈដែលប្រើដើម្បីបង្កើតបាននូវសិទ្ធិទាំងអស់នេះ គឺមានសរសេរនៅក្នុងច្បាប់ក្រមសុខុមាលភាព និងវិទ្យាស្ថាន § 5256.4 ទាំងអស់ ។ (ត្រឡប់ទៅកាន់ឯកសារដើមវិញ)

និងអ្នកដទៃដែលអ្នកស្នើសុំឲ្យប្រាប់អំពីពេលវេលា និងទីកន្លែងសវនាការ ។ បុគ្គលិករបស់មន្ទីរព្យាបាល ក៏ត្រូវតែផ្តល់ដំណឹងដល់អ្នក ឲ្យបានដឹងថា អ្នកមានសិទ្ធិស្នើសុំមិនឲ្យផ្តល់ដំណឹងនេះដល់សមាជិកគ្រួសារ ឬអ្នកដទៃដែលអ្នកមិនចង់ឲ្យមកចូលរួមក្នុងសវនាការ ។

បើអ្នកមិនចង់ទទួលការព្យាបាលទេ អ្នកត្រូវបង្ហាញឲ្យគេដឹងអំពីបំណងនេះ ។ បើទោះបីជាក្នុងករណីខ្លះ អ្នកជម្ងឺប្រឆាំងនឹងការព្យាបាល ដោយសារតែរោគចិត្តរបស់ខ្លួនក៏ដោយ ក៏ការប្រឆាំងចំពោះការព្យាបាល មិនមែនជាភស្តុតាងបង្ហាញអំពីស្ថានភាពរោគចិត្តរបស់អ្នកជម្ងឺ ឬជាភស្តុតាងបញ្ជាក់ពីតម្រូវការទទួលការព្យាបាលឡើយ ។ ក្នុងន័យមួយទៀត បើសិនជាមិនមានភស្តុតាងផ្សេងទៀតមកបញ្ជាក់ បំណងរបស់អ្នកតែមួយមុខក្នុងការមិនព្រមទទួលការព្យាបាល មិនអាចមានភាពគ្រប់គ្រាន់ក្នុងការបង្ហាញថា អ្នកត្រូវតែទទួលការព្យាបាលឡើយ ។

### សិទ្ធិក្នុងការស្នើសុំ 'ឡើងតុលាការ-Habeas Corpus'

សិទ្ធិក្នុងការស្នើសុំឡើងតុលាការ អនុញ្ញាតឲ្យអ្នកអាចតតាំងចំពោះការឃុំខ្លួនអ្នក ដោយការអះអាងថា គេឃុំខ្លួនអ្នកដោយខុសច្បាប់ ។ សវនាការបែបនេះ មិនកើតឡើងបានដោយស្វ័យប្រវត្តិឡើយ។ អ្នកត្រូវតែធ្វើការស្នើសុំដោយជាក់លាក់ ដោយការផ្តល់ដំណឹងដល់សមាជិកក្រុមព្យាបាលរូបអ្នក និងមន្ទីរពេទ្យ ឬក្រុមតស៊ូមតិដើម្បីសិទ្ធិអ្នកជម្ងឺឲ្យបានដឹង ។ បើអ្នកស្នើសុំសវនាការ គឺអ្នកមានសិទ្ធិទទួលបានមេធាវីដែលតែងតាំងដោយតុលាការ ឬមេធាវីឯកជន ។ តែអ្នកត្រូវតែដឹងថា ***សវនាការដើម្បីបញ្ជាក់ថាគេឃុំខ្លួនអ្នកដោយខុសច្បាប់ អាចនាំឲ្យគេពន្យារការឃុំខ្លួនអ្នក ឬក៏ចេញជាផលវិបាកផ្សេងពីនេះទៀត ។*** ត្រូវពិភាក្សាជាមួយមេធាវី ឬក្រុមតស៊ូមតិដើម្បីសិទ្ធិអ្នកជម្ងឺ អំពីលទ្ធផលដែលអាចកើតឡើង នៅមុនពេលស្នើសុំសវនាការ ។ ក្រមសុខុមាលភាព និងវិទ្យាស្ថាន §§ 5254.1, 5275-5276 ។

### លទ្ធផលពីការឃុំខ្លួនចំនួន 14 ថ្ងៃ

អាចកើតចេញជាលទ្ធផលមួយចំនួន នៅចុងបញ្ចប់នៃការឃុំខ្លួនអ្នកចំនួន 14 ថ្ងៃ ៖

- គេអាចដោះលែងអ្នកមុនពេលកំណត់ចំនួន 14 ថ្ងៃ ។ អ្នកអាចទទួលការដោះលែងពីបុគ្គលិកពេទ្យ ឬអាចទទួលការដោះលែងក្នុងពេលធ្វើសវនាការបញ្ជាក់ការសម្រេចឃុំខ្លួនអ្នក ឬអាចទទួលការដោះលែងក្នុងសវនាការបញ្ជាក់ថាគេឃុំខ្លួនអ្នកដោយខុសច្បាប់ (នេះគឺជាសវនាការដែលអ្នកស្នើសុំឲ្យចៅក្រម ពិនិត្យឡើងវិញពីភាពស្របច្បាប់ចំពោះការឃុំខ្លួនអ្នក ។ ឧទាហរណ៍ ចៅក្រមអាចសម្រេចដោះលែងរូបអ្នក បើគេរំលោភសិទ្ធិរបស់អ្នក ក្នុងអំឡុងពេលដំណើរការចាប់ខ្លួនអ្នកមកឃុំទុក) ឬ
- អ្នកត្រូវបន្តស្ថិតនៅទីនោះ ក្នុងនាមជាអ្នកជម្ងឺស្ម័គ្រចិត្តចូលទទួលការព្យាបាល ឬ
- ប្រសិនបើ បុគ្គលដែលព្យាបាលរូបអ្នក កំណត់ឃើញថា អ្នកត្រូវការព្យាបាលបន្ថែមទៀត អ្នកអាចត្រូវឃុំខ្លួនម្តងទៀត ។

ប្រសិនបើ បុគ្គលដែលព្យាបាលរូបអ្នក កំណត់ឃើញថា គេត្រូវឃុំខ្លួនអ្នកយូរជាងនេះ ដើម្បីផ្តល់ការព្យាបាល រយៈពេលនៃការឃុំខ្លួននេះ គឺអាស្រ័យលើមូលហេតុនៃការឃុំខ្លួនអ្នក ។ ក្រោមប្រភេទនៃការឃុំខ្លួននីមួយៗ គឺអ្នកមានសិទ្ធិស្នើសុំសវនាការគ្រប់ការបន្តឃុំខ្លួនអ្នកទាំងអស់ ។

**បើគេនៅតែមើលឃើញថា អ្នកនៅតែអាចបង្កគ្រោះថ្នាក់ដល់ខ្លួនឯង** គេអាចសម្រេចឡើងវិញក្នុងការឃុំខ្លួនអ្នកចំនួន 14 ថ្ងៃបន្ថែមមួយលើកទៀត ។ ក្រមសុខុមាលភាព និងវិទ្យាស្ថាន § 5260 ។

**បើគេនៅតែមើលឃើញថា អ្នកនៅតែអាចបង្កគ្រោះថ្នាក់ចំពោះអ្នកដទៃ** តុលាការអាចដាក់កំណត់ឲ្យឃុំខ្លួនអ្នកចំនួន 180ថ្ងៃ ក្រោយបញ្ចប់ការសម្រេចឲ្យឃុំខ្លួនអ្នកកាលពីមុន ។ ការសម្រេចឃុំខ្លួនអ្នក អាចបន្តឡើងវិញបាន ។ ក្រមសុខុមាលភាព និងវិទ្យាស្ថាន § 5301 ។

**បើគេនៅតែមើលឃើញថា អ្នកនៅតែជាមនុស្សមានពិការភាពធ្ងន់ធ្ងរ** ក្រោយការឃុំខ្លួនអ្នក អាចចេញលទ្ធផលមួយចំនួន ៖

- គេអាចឃុំខ្លួនអ្នកចំនួន 30 ថ្ងៃ ដើម្បីទទួលការព្យាបាលបន្ថែម បើគេធ្វើឡើងក្នុងខោនធីរបស់អ្នក ។ ក្រមសុខុមាលភាព និងវិទ្យាស្ថាន § 5270 et seq. ឬ
- អ្នកអាចត្រូវស្ថិតក្រោមការមើលថែទាំពីមនុស្សដែលតុលាការតែងតាំងជាបណ្តោះអាសន្ន រួចត្រូវស្ថិតក្រោមការមើលថែទាំពីមនុស្សដែលតុលាការតែងតាំងចំនួនមួយឆ្នាំពេញ ដែលស្ថានភាពនេះ អាចបន្តឡើងវិញបានជានិច្ច ។ ក្រមសុខុមាលភាព និងវិទ្យាស្ថាន §§ 5352.1, 5361 ។ ក្នុងករណីនេះ បុគ្គលដែលតុលាការតែងតាំងឲ្យមើលថែទាំអ្នក អាចទទួលបានអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្តមួយចំនួនឲ្យអ្នក ដោយរួមបញ្ចូលនូវការកំណត់ទីកន្លែងឲ្យអ្នករស់នៅ និងការចំណាយប្រាក់របស់អ្នក ។ ក្រមសុខុមាលភាព និងវិទ្យាស្ថាន §§ 5350, 5352 ។ ឬ
- ក្នុងស្ថានភាពខ្លះ ក្រោយពេលគេឃុំខ្លួនអ្នកជម្ងឺបានចំនួន 30 ថ្ងៃ គេអាចដាក់ឯកសារស្នើសុំឲ្យតុលាការតែងតាំងមនុស្សសម្រាប់មើលថែទាំអ្នក ។ ក្នុងស្ថានភាពនេះ ការមើលថែទាំជាបណ្តោះអាសន្នពីបុគ្គលដែលតុលាការតែងតាំង មានដំណើរការស្របពេល(ក្នុងពេលជាមួយគ្នា) ជាមួយនឹងការឃុំខ្លួនអ្នកចំនួន 30 ថ្ងៃ ។ មិនមែនគ្រប់ខោនធីទាំងអស់ សុទ្ធតែដាក់ពេលឃុំខ្លួនអ្នកជម្ងឺចំនួន 30 ថ្ងៃ ឲ្យចូលជាធរមានឡើយ ។ សូមពិគ្រោះបញ្ហានេះ ជាមួយនឹងក្រុមតស៊ូមតិដើម្បីសិទ្ធិអ្នកជម្ងឺ ប្រចាំខោនធីរបស់អ្នក ដើម្បីបានដឹងព័ត៌មានការអនុវត្តដំណើរការឃុំខ្លួនអ្នកជម្ងឺក្នុងខោនធីនេះ ។ ក្រមសុខុមាលភាព និងវិទ្យាស្ថាន § 5256 ។ អ្នកក៏គួរតែអាន “ជំពូកទី 2 ៖ ការមើលថែពីមនុស្សដែលចាត់តាំងដោយតុលាការ ក្រោមច្បាប់ LPS ។

## ព័ត៌មានគន្លឹះដើម្បីចៀសវាងការឃុំខ្លួនក្នុងពេលយូរ

ការត្រូវឃុំខ្លួនដើម្បីទទួលការព្យាបាលរោគចិត្ត គឺជាបទពិសោធន៍មួយដែលពិបាកទទួលយក ។ បើទោះបីជាអ្នកមិនអាចគ្រប់គ្រងបានពេញលេញ ចំពោះលទ្ធផលក៏ដោយ ក៏សកម្មភាពមួយចំនួនខាងក្រោម អាចជួយបង្ហាញថា អ្នកលែងត្រូវការការព្យាបាលជាបន្តទៀតហើយ ៖

**បើគេឃុំខ្លួនអ្នក ដោយសារតែអ្នកអាចបង្កគ្រោះថ្នាក់ចំពោះខ្លួនឯង ៖**

សូមព្យាយាមបញ្ឈប់សកម្មភាពនានាដែលអាចនាំទៅរកការបង្កគ្រោះថ្នាក់ចំពោះខ្លួនឯង ហើយក៏មិនត្រូវធ្វើការគម្រាមណាមួយចំពោះការបង្កគ្រោះថ្នាក់សម្រាប់ខ្លួនអ្នកដែរ ។ បុគ្គលដែលជាអ្នកវាយតម្លៃស្ថានភាពជម្ងឺរបស់អ្នក ជាធម្មតា គេតែងពិនិត្យមើលថាតើអ្នកបានបញ្ឈប់អាកប្បកិរិយាបង្កគ្រោះថ្នាក់ដែរឬទេ **ហើយ** ថាតើបើគេដោះលែងអ្នក អ្នកនឹងអាចបង្កគ្រោះថ្នាក់ចំពោះខ្លួនឯងជាថ្មីទៀតដែរឬទេ ។ វាអាចមានប្រយោជន៍

ក្នុងការប្រាប់ឲ្យបុគ្គលិកមន្ទីរពេទ្យបានដឹងថា តើអ្នកមានគ្រូពេទ្យដែរ ឬមានថ្នាំសម្រាប់លេបដើម្បីបញ្ឈប់រោគសញ្ញាដែលអាចនាំទៅរកអាកប្បកិរិយាបង្កគ្រោះថ្នាក់ដែរឬទេ ក្រោយពេលអ្នកទទួលការដោះលែង ។

**បើគេឃុំខ្លួនអ្នក ដោយសារអ្នកបង្កគ្រោះថ្នាក់ចំពោះអ្នកដទៃ ៖**

ការជាប់ឃុំ អាចជារឿងដែលរកាំចិត្ត និងមានការប៉ះពាល់អារម្មណ៍ តែសូមព្យាយាមកុំឈ្លោះប្រកែក ឬបង្ករឿងជាមួយអ្នកជម្ងឺដទៃ ឬបុគ្គលិកពេទ្យ ។ កុំបង្កជម្លោះ ហើយក៏កុំបណ្ដោយខ្លួនអ្នកឲ្យគេរករឿងបានដែរ ។ កុំរុញ ចាប់ ឬវាយនរណាម្នាក់ ។ កុំប៉ះពាល់អ្នកដទៃ បើបុគ្គលិកមិនបានសុំឲ្យអ្នកធ្វើទេនោះ ។

**បើគេឃុំខ្លួនអ្នកដោយសារមូលហេតុពិការភាពធ្ងន់ធ្ងរ ៖**

អ្នកដែលវាយតម្លៃស្ថានភាពជម្ងឺរបស់អ្នក នឹងពិនិត្យមើលថាតើ អ្នកអាចចាត់ចែងចំពោះតម្រូវការជាមូលដ្ឋានរបស់ខ្លួនបានដែរឬទេ ។ ខណៈពេលដែលអ្នកស្ថិតនៅក្នុងមន្ទីរពេទ្យ សូមយកពេលនេះ សម្រាប់មើលថែទាំខ្លួនឯង ។ ទទួលទានអាហារដែលគេដាក់ឲ្យអ្នកហូប ។ ព្យាយាមគេងឲ្យលក់ ។
បើគេចាប់អ្នកចូលឃុំដោយសារអត់ស្លៀកពាក់ខោអាវ ឬគេដោះខោអាវអ្នកចេញ សូមពាក់ខោអាវដែលមន្ទីរពេទ្យឲ្យអ្នកពាក់ ។ ប្រើបន្ទប់ទឹក និងប្រើទឹកផ្កាឈូកដើម្បីងូតសម្អាតខ្លួនប្រាណ និងអនុវត្តអនាម័យខ្លួនប្រាណជាមូលដ្ឋាន ។

ត្រូវប្រាប់ឲ្យបុគ្គលិកមន្ទីរពេទ្យបានដឹង ថាតើអ្នកអាច ហូបអាហារ ប្រើប្រាស់សម្លៀកបំពាក់ និងផ្ទះរបស់ខ្លួនបានដែរឬទេ ។ បើរបស់ទាំងអស់នេះ មិនមានសម្រាប់អ្នកទេ អ្នកត្រូវព្យាយាមប្រាប់ឲ្យបុគ្គលិកមន្ទីរពេទ្យបានដឹងថា យ៉ាងហោចណាស់ អ្នកដឹងពីរបៀបរកអាហារមកហូប របៀបយកខោអាវមកស្លៀកពាក់ និងរកទីជម្រក ឬក៏ប្រាប់ឲ្យគេបានដឹងថា អ្នកចេះរកជំនួយ ដើម្បីទទួលបានរបស់ទាំងអស់នេះ ។ អ្នកមិនចាំបាច់បង្ហាញថា អ្នកអាចធ្វើកិច្ចការទាំងអស់នេះបាន ដោយខ្លួនឯងឡើយ ។
បើអ្នកមានមនុស្សចាំជួយអ្នកចាត់ចែងតម្រូវការជាមូលដ្ឋានរបស់អ្នក សូមឲ្យអ្នកនោះជួយពន្យល់ដល់តុលាការ ឬមន្ទីរពេទ្យ (ធ្វើជាលាយល័ក្ខណ៍អក្សរបើអាចធ្វើបាន) ពីទំនាក់ទំនងរបស់គេចំពោះអ្នក និងពីរបៀបដែលគេអាចជួយអ្នកចំពោះការងារនេះ ។

**ព័ត៌មានគន្លឹះទូទៅ ដែលអ្នកអាចយកមកពិចារណា**

បើអ្នកស្គាល់នរណាម្នាក់ដែលអាចជួយអ្នកបានចំពោះការព្យាបាល ឬចំពោះតម្រូវការមូលដ្ឋានរបស់អ្នក ឬស្គាល់នរណាម្នាក់ដែលអាចជួយពន្យល់បានថា ហេតុអ្វីអ្នកមិនចាំបាច់សម្រាកពេទ្យ គឺអាចមានប្រយោជន៍ដែលអ្នកត្រូវទាក់ទងជាមួយអ្នកនោះ ។ មនុស្សទាំងអស់នេះ អាចជាមិត្តភ័ក្ដ សមាជិកគ្រួសារ គ្រូពេទ្យ ឬអ្នកណាក៏ដោយដែលអាចជួយនិយាយជំនួសអ្នកបាន ។ បើអ្នកមាននរណាម្នាក់ដែលធ្លាប់ជួយអ្នកកន្លងមក ឬនរណាដែលមានពេល ហើយមានបំណងជួយអ្នក អ្នកនោះត្រូវដាក់លិខិតទៅកាន់តុលាការ ដោយរៀបរាប់អំពីរបៀបដែលគេអាចជួយអ្នក **។ តុលាការ នឹងមិនគិតចំពោះលទ្ធភាពរបស់នរណាម្នាក់ក្នុងការជួយអ្នកឡើយ បើសិនជាមិនមានការបញ្ជាក់ជាលាយល័ក្ខណ៍អក្សរទេនោះ ។** § 5250(d)(2) ។ ទោះជាយ៉ាងណាក៏ដោយ មន្ទីរពេទ្យអាចព្រមនិយាយជាមួយនរណាម្នាក់ តាមទូរស័ព្ទ ។ ព័ត៌មាននេះ ក៏មានសារៈសំខាន់ផងដែរចំពោះក្រុមអ្នកតស៊ូមតិដើម្បីសិទ្ធិអ្នកជម្ងឺ ឬមេធាវីរបស់អ្នក ។ បើគេបើកសវនាការដើម្បីសម្រេចថាតើគេត្រូវឃុំខ្លួនអ្នកយូរជាង 72 ម៉ោងដែរឬទេ បុគ្គលនេះ ឬព័ត៌មានដែលរូបគេផ្ដល់ឲ្យ អាចជួយដល់មន្ត្រីសវនាការ ឬចៅក្រមចំពោះការសម្រេចចិត្តរបស់ពួកគេបាន ។

ខណៈពេលស្ថិតនៅមន្ទីរពេទ្យ គឺអ្នកអាចត្រូវស្ថិតនៅក្នុងបន្ទប់ជាមួយអ្នកជម្ងឺដទៃដែលត្រូវទទួលការព្យាបាល ឬត្រូវឃុំឃាំងដោយសាររោគចិត្តដែរ ។ សូមគោរពឯកជនភាព និងទីកន្លែងផ្ទាល់ខ្លួនរបស់ពួកគេ ជាពិសេសកន្លែងនៅជិតបន្ទប់របស់គិលានុប្បដ្ឋាក បន្ទប់នៅដាច់ពីគេ ទូរស័ព្ទ ទូរទស្សន៍ និងពេលដែលពួកគេទទួលទានអាហារ ។

ពេលនៅក្នុងមន្ទីរពេទ្យ គេអាចមានសកម្មភាពឲ្យអ្នកធ្វើ ។ បើទោះបីជាគេមិនតម្រូវឲ្យអ្នកចូលរួមក៏ដោយ ការចូលរួមសកម្មភាពបានកាន់តែច្រើន វានឹងបង្ហាញឲ្យបុគ្គលិកមន្ទីរពេទ្យដឹងថា អ្នកអាចទំនាក់ទំនងជាមួយមនុស្សដទៃបានដោយសុវត្ថិភាព ។ សកម្មភាពទាំងអស់នេះ ក៏អាចមានប្រយោជន៍ចំពោះខ្លួនអ្នកផ្ទាល់ដែរ ដោយជួយកាត់បន្ថយភាពតានតឹងផ្លូវចិត្ត ឬក៏ដើម្បីបំភ្លេចពេលវេលាអផ្សុកចេញពីខួរក្បាលក្នុងពេលជាប់ឃុំ ។

---

យើងខ្ញុំចង់ស្តាប់យោបល់អ្នក! សូមជួយបំពេញសំណួរសម្រង់មតិខាងក្រោម ស្តីអំពីការបោះពុម្ពផ្សាយរបស់យើងខ្ញុំ ហើយប្រាប់ឲ្យយើងខ្ញុំបានដឹងពីគុណភាពការងាររបស់យើងខ្ញុំ! [ចាប់ផ្តើមបំពេញសំណួរសម្រង់មតិ]

សម្រាប់ជំនួយផ្លូវច្បាប់ សូមហៅមកលេខ 800-776-5746 ឬបំពេញ បែបបទស្នើសុំជំនួយ ។
សម្រាប់គោលបំណងផ្សេងៗទៀតទាំងអស់ សូមហៅទូរស័ព្ទមកលេខ 916-504-5800 (កាលីហ្វ័រនីញ៉ាខាងជើង) 213-213-8000 (កាលីហ្វ័រនីញ៉ាខាងត្បូង) ។

*Disability Rights California បានទទួលមូលនិធិឧបត្ថម្ភពីប្រភពផ្តល់ជំនួយមួយចំនួន ។ សម្រាប់បញ្ជីលម្អិតនៃអ្នកផ្តល់ជំនួយ សូមទស្សនាគេហទំព័រ*
http://www.disabilityrightsca.org/Documents/ListofGrantsAndContracts.html ។